


# គម្រោងគាំទ្រអង្គការសង្គមស៊ីវិល មូលនិធិសម្រាប់ចង្កោមអង្គការសង្គមស៊ីវិល

## ទិដ្ឋភាពទូទៅ

ការរួមបញ្ចូលគ្នានៃវិសាលភាព និងវិធីសាស្ត្រផ្សេងៗនៃចង្កោមអង្គការ និងស្ថាប័ន - អង្គការទិន្នន័យអំពីការអភិវឌ្ឍ ខេមបូចា អង្គការថែរក្សាភាសាជនជាតិដើមភាគតិច និង អេកូយុវទូតនឹងពង្រឹងការផ្សព្វផ្សាយទូលំទូលាយទាំងថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។

ចង្កោមអង្គការសង្គមស៊ីវិល នឹងធ្វើឱ្យការគ្រប់គ្រងធនធានធម្មជាតិកាន់តែមាននិរន្តរភាព បរិយាបន្ន សង្គម ព្រមទាំងការចូលរួម ដោយរួមបញ្ចូលតម្រូវការ និងកង្វល់របស់ក្រុមជនជាតិដើមភាគតិច។ គម្រោងនេះកើតចេញពីការខ្វះតម្លាភាពក្នុងដំណើរការធ្វើការសម្រេចចិត្តដោយមានការចូលរួម និងការត្រួតពិនិត្យការគ្រប់គ្រងធនធានធម្មជាតិ ការការពារបរិស្ថាន និងភាពងាយរងគ្រោះរបស់ជនជាតិដើមភាគតិចនៅក្នុងដំណើរការបែបនេះ។

## គោលបំណង

១. **កែលម្អលទ្ធភាពទទួលបានទិន្នន័យទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ និងការការពារបរិស្ថានប្រកបដោយអត្ថន័យ និងអាចទុកចិត្តបាន**
ដើម្បីរក្សាភាពទទួលខុសត្រូវរបស់ក្រុមហ៊ុន និងរដ្ឋាភិបាល ក៏ដូចជារាយការណ៍អំពីបញ្ហាដែលសហគមន៍ជនជាតិដើមភាគតិចបានជួបប្រទះ។

២. **ប្រមូលផ្តុំសហគមន៍ជនជាតិដើមភាគតិច**
កែលម្អយន្តការទំនាក់ទំនងរវាងជនជាតិដើមភាគតិច និងអាជ្ញាធរមូលដ្ឋាន ព្រមទាំងគាំទ្រពួកគេឱ្យចូលរួមយ៉ាងសកម្មក្នុងការសម្រេចចិត្តជាសាធារណៈនៅថ្នាក់ក្រោមជាតិ។

៣. **ជំរុញការគ្រប់គ្រងធនធានធម្មជាតិនៅថ្នាក់ជាតិ**
បង្កើតសម្ព័ន្ធភាពជាយុទ្ធសាស្ត្រ ជាមួយអ្នកពាក់ព័ន្ធគ្រប់វិស័យសំខាន់ៗ ដោយធានាថាទស្សនៈរបស់ជនជាតិដើមភាគតិចត្រូវបានឆ្លុះបញ្ចាំងយ៉ាងមានប្រសិទ្ធភាព។

## អ្នកអនុវត្តគម្រោង

អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី)

## ចង្កោមអង្គការ និងស្ថាប័ន

- ខេមបូចា
- អង្គការថែរក្សាភាសាជនជាតិដើមភាគតិច
- អេកូយុវទូត

## គាំទ្រមូលនិធិដោយ

ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) តាមរយៈអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360)

## ថវិកា

១៩៩.៨៥៧ ដុល្លារអាមេរិក

## រយៈពេលគម្រោង

១៥ កក្កដា ២០២២ – ៣១ ធ្នូ ២០២៤

## តំបន់គោលដៅ

ខេត្តមណ្ឌលគិរី ព្រះវិហារ រតនគិរី ស្ទឹងត្រែង ពោធិ៍សាត់ និងកោះកុង

## សកម្មភាព



- កិច្ចប្រជុំប្រចាំត្រីមាស
- កិច្ចប្រជុំបង្កោមអង្គការប្រចាំខែ
- ទំនាក់ទំនងរវាងជនជាតិដើមភាគតិច និងអាជ្ញាធរមូលដ្ឋាន



- ផែនទីគម្របព្រៃ ២០១៥-២០២០
- ផែនទីគ្រប់គ្រងធនធានធម្មជាតិ
- បច្ចុប្បន្នភាពសំណុំទិន្នន័យគ្រប់គ្រងធនធានធម្មជាតិ



- ការនិទានរឿងដោយប្រើប្រាស់ទិន្នន័យ
- ការផលិតវីដេអូខ្លីៗ
- ការប្រើប្រាស់ទូរស័ព្ទដៃសរសេរព័ត៌មាន
- គណៈកម្មាធិការជនជាតិដើមភាគតិច



- របាយការណ៍ពិសេស
- យុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយសង្គម
- ការបង្ហាញវីដេអូដោយចល័ត
- យុទ្ធនាការផ្សព្វផ្សាយ
- ការពិភាក្សាតាមបែបវិទ្យាសាស្ត្រ



- ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ
- គាំទ្រកម្មវិធីបរិស្ថាន
- កិច្ចសន្ទនា
- កិច្ចប្រជុំថ្នាក់ជាតិស្តីពីការគ្រប់គ្រងធនធានធម្មជាតិ



- របាយការណ៍បរិស្ថាន
- បណ្ណាល័យ
- ឧបករណ៍ព័ត៌មាន អប់រំ និងទំនាក់ទំនង
- គោលការណ៍សង្ខេបស្តីពីការគ្រប់គ្រងធនធានធម្មជាតិ

## អ្នកទទួលផល



~ ១.៨០០នាក់

(ដោយផ្ទាល់ពីគម្រោង)




~ ៣៦.០០០នាក់ចូលមើល

(ទំព័រព័ត៌មានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងគម្របព្រៃឈើ)



មនុស្សជាច្រើននាក់

(ដោយប្រយោលពីគម្រោង)


## ព័ត៌មានទំនាក់ទំនង

**លោក ធី ទ្រី**
នាយកប្រតិបត្តិ/និពន្ធនាយក
try@opendevcam.net

**អ្នកស្រី គឹម ឈួនវួច**
បណ្ណាធិការ-អ្នកស្រាវជ្រាវផ្នែកធនធានធម្មជាតិ និងដីធ្លី / អ្នកសម្របសម្រួលគម្រោង
chhuonvuoch@opendevcam.net

(+855) 23 902 196 | contact@opendevcam.net | www.opendevelopmentcambodia.net | @OpenDevCam | @OpenDevCam


Photo: Mr. Lukas Bergstrom

ខែតុលា ឆ្នាំ២០២២